# ៤—ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និង កីឡា

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ៦២៨ អយក.ប្រក**

**ស្តីពីការកំណត់មណ្ឌលប្រលងសញ្ញាប័ត្រ**

**មធ្យមសិក្សាកំរិតសិក្សាទី ២ លើកទី ២**

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

–បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១.១១.៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

– បានឃើញព្រះរាជក្រឹត្យលេខ ១០៩៤.៩០ នស.រកត ចុះថ្ងៃទី ៣១.១០.៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។

–បានឃើញច្បាប់ស្តីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០–៧–៩៤

–បានឃើញលិខិតខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ២២៣៧ សជណ.អរ ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ១៩៩០ ស្តីពីការប្តូរឈ្មោះសាលាចំណេះទូទៅ

–បានឃើញប្រកាសរបស់ក្រសួងអប់រំ យុវជន និង កីឡាលេខ ១១៦ អយក.ប្រក ចុះថ្ងៃ០៦–២–៩៦ ស្តីពីការរៀបចំប្រព្រឹត្តិទៅនៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ២

–យោងសំណើរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ស្តីពីការសុំបើក មណ្ឌលប្រលងសញ្ញាប័ត្រ មធ្យមសិក្សាកំរិត ២ តាមខេត្ត–ក្រុង

**សំរេច**

**ប្រការ ១** : មណ្ឌលប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ ចំនេះទូទៅនិងបំពេញវិជ្ជាលើកទី២ សម័យប្រលងថ្ងៃទី ២២-៧-៩៦ ត្រូវកំនត់ដូចតទៅ ÷

**I - រាជធានីភ្នំពេញមាន ៣ មណ្ឌល :**

១-មណ្ឌល អនុវិ. ចតុមុខ ៣៤ បន្ទប់

២-មណ្ឌល វិ. បឹងត្របែក ២៦ បន្ទប់

៣-មណ្ឌលវិ. ព្រះស៊ីសុវត្ថិ ៦០ បន្ទប់ ក្នុងនោះបំ.វិ. ៦ បន្ទប់ និង ស្វ័យរិន ១២ បន្ទប់

**II - ខេត្តកណ្ដាលមាន ២ មណ្ឌល :**

១-មណ្ឌល ជ័យវរ្ម័នទី ៧ ២៥ បន្ទប់

២-មណ្ឌល បឋម. ដីឥដ្ឋ ១២ បន្ទប់ ក្នុងនោះបំ.វិ ១ បន្ទប់

**III - ខេត្តតាកែវ មាន ១ មណ្ឌល :**

១-មណ្ឌលវិ. ជាស៊ីមតាកែវ ២០ បន្ទប់ ក្នុងនោះស្វ័យរិន ២ បន្ទប់

**IV - ខេត្តកំពតមាន ១ មណ្ឌល :**

១-មណ្ឌលវិ. ព្រះរាជសម្ភារ ១៥ បន្ទប់

**V - ក្រុងព្រះសីហនុ មាន ១ មណ្ឌល :**

១-មណ្ឌល អនុវិ. សម្ដេចឱ ៥បន្ទប់

**VI - ខេត្តកំពង់ស្ពឺមាន ១ មណ្ឌល :**

១-មណ្ឌល វិ. កំពង់ស្ពឺ ៦ បន្ទប់ ក្នុងនោះស្វ័យរិន ២ នាក់

**VII - ខេត្តព្រៃវែង មាន ១ មណ្ឌល :**

១-មណ្ឌលវិទ្យាល័យព្រះអង្គឌួង ២០ បន្ទប់ ក្នុងនោះ ស្វ័យរិន ២ បន្ទប់

**VIII - ខេត្តស្វាយរៀង មាន ១ មណ្ឌល :**

១-មណ្ឌលវិ. ស្វាយរៀង ១១ បន្ទប់

**IX - ខេត្តកំពង់ឆ្នាំង មាន ១ មណ្ឌល :**

១-មណ្ឌលវិ. ព្រះបាទសុរាម្រិត ៨ បន្ទប់

**X - ខេត្តពោធិ៍សាត់ មាន ១ មណ្ឌល :**

១–មណ្ឌលវិ.ពោធិសាត់ ៦ បន្ទប់ក្នុងនោះមាន បំ.វិ. ៤ នាក់

**XI - ខេត្តបាត់ដំបង មាន ១ មណ្ឌល :**

១–មណ្ឌលវិ.ព្រះមុនីវង្ស ៣៧ បន្ទប់ ក្នុងនោះបំ.វិ.៣បន្ទប់ និង ស្វ័យវិន ៤ បន្ទប់

**XII - ខេត្តបន្ទាយមានជ័យ មាន ១ មណ្ឌល :**

១–មណ្ឌលវិ.សម្តេចឱ ១៤ បន្ទប់ក្នុងនោះបំ.វិ.១ បន្ទប់

**XIII - ខេត្តកំពង់ធំ មាន ១ មណ្ឌល :**

១–មណ្ឌលវិ.កំពង់ធំ ២២ បន្ទប់ ក្នុងនោះបំ.វិ.១ បន្ទប់

**XIV - ខេត្តកំពង់ចាម មាន ១ មណ្ឌល :**

១–មណ្ឌល វិ.ព្រះសីហនុ ៥១ បន្ទប់ ក្នុងនោះបំ.វិ. ១ បន្ទប់

**XV - ខេត្តក្រចេះ មាន ១ មណ្ឌល :**

១–មណ្ឌលវិ.ព្រះមហាក្សត្រីយានីកុសមៈ ៩ បន្ទប់ ស្វ័យវិន ១ បន្ទប់

**XVI - ខេត្តសៀមរាប មាន ១ មណ្ឌល :**

១–មណ្ឌលអនុវិ.អង្គរ ១៨ បន្ទប់ ក្នុងនោះបំ.វិ. ១ បន្ទប់

**XVII - ខេត្តស្ទឹងត្រែង មាន ១ មណ្ឌល :**

១–មណ្ឌលវិ.ព្រះរាជបូជនីយកិច្ច ១ បន្ទប់

**XVIII - ខេត្តកោះកុង មាន ១ មណ្ឌល :**

១–មណ្ឌលវិ.កោះកុង ២ បន្ទប់

**XIX - ខេត្តព្រះវិហារមាន ១ មណ្ឌល :**

១–មណ្ឌលវិ.ត្បែងមានជ័យ ១ បន្ទប់

**XX - ខេត្តរតនគិរី មាន ១ មណ្ឌល :**

១–មណ្ឌលវិ.សម្តេចឱ–សម្តេចម៉ែ ១ បន្ទប់

**ប្រការ ២** : ប្រធានមន្ទីរអប់រំយុវជននិងកីឡាខេត្ត–ក្រុង និងនាយកគ្រឹះស្ថានសិក្សាដែលគ្រឹះស្ថានសិក្សារបស់ខ្លួន ត្រូវយកធ្វើជាមណ្ឌលប្រលងមានភារៈកិច្ច រៀបចំមណ្ឌលប្រលង សៀវភៅកំណត់រូបថតបេក្ខជន បញ្ជីផ្សេងៗ និង សំភារៈចាំបាច់សំរាប់

ការប្រព្រឹត្តិទៅនៃការប្រលងអោយ ហើយស្រេចមុនបើកសម័យប្រលង ។

**ប្រការ ៣** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានអប់រំក្រៅប្រពន្ធ័ ប្រធាននាយកដ្ឋានផែនការ ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងអប់រំយុវជន និង កីឡា ត្រូវអនុវត្តភារកិច្ចរៀងៗ ខ្លួន ដើម្បីអោយបានសំរេចតាមប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**តុល ឡោះ**

* * *

## ៥—ទីស្តីការរដ្ឋមន្ត្រីក្រសួងបរិដ្ឋាន

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ១០៥៧ ប.ស្ត**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

រដ្ឋមន្ត្រីក្រសួងបរិដ្ឋាន

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ**នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១.១១.៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។

– បានឃើញច្បាប់ស្តីពីការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ កក្កដា ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០–៧–៩៤

– បានឃើញព្រះរាជក្រម នស.រកម ០១៩៦ ២១ ស្តីពីប្រកាសអោយប្រើច្បាប់ស្តីពីការ បង្កើតក្រសួងបរិស្ថាន ចុះថ្ងៃទី២៤–០១–៩៦